00581357

E189.1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

លោកចៅក្រម និល ណុន

ប្រធានអង្គជំនុំជម្រះសាលាដំបូងនៅ អ.វ.ត.ក

ភ្នំពេញ ប្រទេសកម្ពុជា

ភ្នំពេញ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១០

**កម្មវត្ថុ៖ការចាត់តាំងភារកិច្ចជាអចិន្ត្រៃយ៍ជូនលោក កង ឫទ្ធារី**

លោកចៅក្រមជាទីរាប់អាន

ខ្ញុំ សូមជម្រាបលោកថាលោក កង ឫទ្ធារី សមាជិកគណៈមេធាវីកម្ពុជា ត្រូវបានជ្រើសរើសឲ្យមកការពារក្តីលោក កាំង ហ្កេកអ៊ាវ ជាមួយលោក ការ សាវុត្ថ។ កិច្ចសន្យាផ្តល់សេវាកម្មផ្នែកច្បាប់ដើម្បីការពារក្តីនេះចាប់ផ្តើមពីពេលនេះតទៅ។

ដោយសារតែបច្ចុប្បន្ននេះ បញ្ហាទាក់ទងនឹងនីតិវិធីទាំងអស់ត្រូវបញ្ចប់ ខ្ញុំសូមចាត់តាំងលោក កង ឫទ្ធារី ជាសហមេធាវីជាតិទី២ដើម្បីការពារក្តីជូនលោក កាំង ហ្កេកអ៊ាវ ជាអចិន្ត្រៃយ៍។

អនុលោមតាមកថាខណ្ឌ៦.២ នៅក្នុងបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការការពារក្តី ខ្ញុំបានភ្ជាប់មកជាមួយនូវទម្រង់៧ (សំណើសុំចាត់តាំងសហមេធាវី) ដែលត្រូវបានបំពេញទាន់ពេលវេលាដោយលោក កាំង ហ្កេកអ៊ាវ និងខ្លួនខ្ញុំផ្ទាល់ និងសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងអនុម័តនូវការចាត់តាំងភារកិច្ចជាអចិន្ត្រៃយ៍នេះជូនលោក កង ឫទ្ធារី ជាសហមេធាវីការពារក្តីជូនលោក កាំង ហ្កេកអ៊ាវ និងដើម្បីឲ្យ អ.វ.ត.ក អនុញ្ញាតឲ្យគាត់បំពេញភារកិច្ចដែលបានចាត់តាំងនេះ អនុលោមតាមមាត្រា២១(១) នៃកិច្ចព្រមព្រៀង។

សូមលោកចៅក្រមទទួលនូវការរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

Richard J Rogers

ប្រធានអង្គភាពគាំពារការការពារក្តី

ចម្លងជូន៖លោក កង ឫទ្ធារី

លោក ការ សាវុត្ថ

លោក កាំង ហ្កេកអ៊ាវ